CAMBODIA-AMERICA ALLIANCE
សម្ព័ន្ធមិត្តខ្មែរ-អាមេរិកាំង
P.O. Box 16338 | High Point | NC 27261
t: 1-202-780-5299 | e: Info@CambodiaAmerica.Org
w: www.CambodiaAmerica.org | page: Cambodia-America-Alliance

លេខ: ០០១/២០១៧ ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៧

# សេចក្ដីថ្លែងការណ៍

## ច្បាប់ស្ដីពីគណបក្សនយោបាយ: ផ្លូវឆ្ពោះទៅរករដ្ឋដែលគ្រប់គ្រងដោយគណបក្សតែមួយ

ការធ្វើវិសោធនកម្មច្បាប់ស្ដីពីគណបក្សនយោបាយដែលបានអនុម័តដោយគណបក្សប្រជាជនកម្ពុជានៅថ្ងៃនេះដោយគ្មានការចូលរួមពីគណបក្សសង្គ្រោះជាតិគឺជាការប៉ុនប៉ងចុងក្រោយបង្អស់ពីនាយករដ្ឋមន្ត្រី ហ៊ុន សែន ដើម្បីលុបបំបាត់គណបក្សប្រឆាំងនានា ហើយជម្រុញរបបមួយនេះខិតកាត់តែគៀកទៅរករដ្ឋដែលមានតែគណបក្សមួយ ។ ការធ្វើវិសោធនកម្មនេះបានផ្ដល់អំណាចទៅឲ្យតុលាការមានសិទ្ធិសម្រេចរំលាយគណបក្សណាដែលមេដឹកនាំមានពិរុទ្ធភាព ។ ជាក់ស្ដែងនៅចំពោះមុខ លោក សម រង្ស៊ី បានទទួលរងពាក្យបណ្ដឹងរាប់មិនអស់ពី នាយករដ្ឋមន្ត្រី ហ៊ុន សែន និងគ្នីគ្នារបស់គាត់ ។ ស្ទើរតែចាញ់ការបោះឆ្នោតទៅគណបក្សសង្គ្រោះជាតិនៅឆ្នាំ២០១៣ គណបក្សប្រជាជនកម្ពុជាឥឡូវនេះកំពុងតែប្រើឥទ្ធិពលរបស់ខ្លួនទៅលើតុលាការដើម្បីចាប់ និងកាត់ទោសអ្នកជំទាស់ សមាជិកអង្គការក្រៅរដ្ឋាភិបាល សកម្មជននានា និង សមាជិកគណបក្សសង្គ្រោះជាតិដោយគ្មានត្រាប្រណី ។

អង្គការសម្ព័ន្ធមិត្តខ្មែរ-អាមេរិកាំងសូមថ្កោលទោសចំពោះការអនុម័តច្បាប់គណបក្សនយោបាយនេះ ។ ការអនុម័តច្បាប់នេះឆ្លុះបញ្ចាំងកង្វះខាតការប្ដេជ្ញាចិត្ត និងការមិនឲ្យតម្លៃទៅសេរីពហុបក្សពីសំណាក់នាយករដ្ឋមន្ត្រី ហ៊ុន សែន ។ ចំណាត់ការនានារបស់គាត់ រួមជាមួយនឹងច្បាប់ថ្មីនេះរឹតតែបង្ហាញការមិនគោរពនៃទស្សនៈ និងគោលការណ៏លិទ្ធិប្រជាធិបតេយ្យដែលមានចែងក្នុងកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស អនុសញ្ញាអង្គការសហប្រជាជាតិ និងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រខ្លួន ។ យើងសូមកោតសរសើរតំណាងរាស្ត្រ អាលែន ឡូវិនថល ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក វីលៀម ហេដ និងអង្គការក្រៅរដ្ឋាភិបាលជាច្រើនទៀតក្នុងការសម្ដែងប្រឆាំងនឹងការអនុម័តច្បាប់នេះ ។ ទោះជាយ៉ាងណា នេះជាការចាំបាច់បំផុតដែលសហគមន៏អន្តរជាតិត្រូវមានចំណាត់ការប្រកបដោយការទទួលខុសត្រូវដើម្បីបញ្ចៀសផ្លូវដ៏គ្រោះថ្នាក់របស់កម្ពុជាឆ្ពោះទៅរករដ្ឋផ្ដាច់ការ ។ ប្រសិនបើប្រវត្តិសាស្ត្រមិនទាន់សាបសូន្យនោះទេ នាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រើកលល្បិចបែបនេះជាច្រើនលើកច្រើនសារដើម្បីបំភិតបំភ័យក្រុមជំទាស់ ស្របពេលប្រទេសម្ចាស់ជំនួយនៅតែបន្តផ្ដល់ជំនួយបរទេស ។

ការលាលែងរបស់លោក សម រង្ស៊ី អតីតប្រធានគណបក្សសង្គ្រោះជាតិកាលពីសប្ដាហ៍មុននេះក្រោមហេតុផលពីការអនុម័តច្បាប់នេះ នឹងមិនអាចការពារគណបក្សសង្គ្រោះជាតិពីការចោទប្រកាន់ និងកាត់ទោសពីសំណាក់តុលាការក្រោមការគ្រប់គ្រងដោយគណបក្សប្រជាជនកម្ពុជាបានទេ ។ អង្គការសម្ព័នមិត្តខ្មែរ-អាមេរិកាំងសូមអំពាវនាវសហគមន៏អន្តរជាតិ ជាពិសេសប្រទេសផ្ដល់ជំនួយត្រូវចាត់វិធានការឲ្យបានម៉ឺងម៉ាត់មិនត្រឹមតែដាក់សំពាធនាយករដ្ឋមន្ត្រី ហ៊ុន សែន ឲ្យលុបចោលច្បាប់ថ្មីនេះទេ តែត្រូវធានាថា នាយករដ្ឋមន្ត្រី ហ៊ុន សែន និងគណបក្សរបស់គាត់គោរព និងរក្សាសេរីពហុបក្សគ្រប់ពេលវេលា ។

###